# មួយអាទិត្យ

(បទពាក្យ៧)

ថ្ងៃច័ន្ទចងចាំបណ្ដាំពុក    បោះជើងទៅមុខឥតរួញរា<br>
តាំងចិត្តសិក្សាសព្វវិជ្ជា    រក្សានាមាជូនពង្សផៅ។<br>
អង្គារអំណត់ឥតអល់អែក    តស៊ូបំបែកភាពល្ងង់ខ្លៅ<br>
តាំងចិត្តប្រព្រឹត្តតាមសំណៅ    ពុកម៉ែប្រដៅប្រាប់ផ្លូវល្អ។<br>
ថ្ងៃពុធខំពត់លត់ដំកាយ    មិនហិចសប្បាយហ៊ឺឈូឆរ<br>
វិថីសុចរិតគិតត្រាច់ចរ    រៀនសូធ្យបន្តបវរគាប់។<br>
ព្រហស្បតិ៍ប្រហែសក្រែងកុនខ្លួន    គួរគិតថៃធ្នូនច្បាប់ទំលាប់<br>
ខំស្វែងវិជ្ជាលំអភ័ព្វ    លោកថាជាទ្រព្យជាប់តាមប្រាណ។<br>
ថ្ងៃសុក្រកុំសុញតុញគំនិត    ឧស្សាហ៍រិះគិតរកចំណាន<br>
បង្កើនចំណេះអោយថ្កើងថ្កាន    ដេញខ្ជិលអោយបានផុតមូទូ។<br>
ថ្ងៃសៅរ៍បន្សាបអសីលធម៌    កុំក្រអឺត ត មើលងាយគ្រូ<br>
គុណឪពុកម្ដាយគួរគិតគូរ    ជាកតញ្ញូជនកល្យាណ។<br>
អាទិត្យជីវិតពិតបវរ    មានចិត្តស្មោះសរចេះប្រមាណ<br>
រក្សាវិជ្ជាដែលរៀនបាន    ខំកសាងប្រាណអោយបានល្អ។✍

*០៦ មករា ២០០៣*

*ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម*